**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**


ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១១១៧ សហវ.ទស


រាជធានីភ្នំពេញថ្ងៃទី ០៧ ខែ មីនា ឆ្នាំ២០១១

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម**

**កម្មវត្ថុ:** សំណើសុំថវិកាបដិភាគចំនួន ៦០,០០០ដុល្លារអាមេរិក (ហុកសិបពាន់ដុល្លារអាមេរិក) ។

**យោង:** លិខិតលេខ ១៤០ ធទឧ ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹក និងឧតុនិយម។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមឯកភាពធានាចំណាយថវិកាបដិភាគរបស់រាជរដ្ឋាភិបាលសម្រាប់ជំហានទី ២ រយៈពេល ០១ឆ្នាំ (២០១១)ទៀត ដែលមានទឹកប្រាក់ចំនួន ៦០,០០០ដុល្លារអាមេរិក (ហុកសិបពាន់ដុល្លារអាមេរិក) ជូនក្រសួងធនធានទឹក និងឧតុនិយមដើម្បីចូលរួមចំណែកក្នុងការអនុវត្តគម្រោងកែលំអការអភិវឌ្ឍន៍និងការគ្រប់គ្រងអាងស្ទឹងសម្រាប់កសិកម្មដំណាក់កាលទី ៣ (The Improvement of Agricultural River Basin Management and Development Project-TSC 3) ។

ចំពោះគម្រោងចំណាយសម្រាប់ឆ្នាំ ២០១២-២០១៤ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមស្នើឲ្យក្រសួងធនធានទឹក និងឧតុនិយមដាក់ក្នុងផែនការចំណាយថវិកាចរន្តប្រចាំឆ្នាំវិញ៕

អាស្រ័យហេតុនេះ សូមឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាប និងមានវិធានការ តាមការគួរ។

សូមឯកឧត្តមមេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

គាត ឈន់


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា

St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.

www.mef.gov.kh

ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨

Phone : 855-23-724 664 Fax : 855-23-427 798

mef_adm@yahoo.com